**តុលាការខេត្តព្រះសីហនុ**

<u>សាលក្រម</u>

លេខ ៩៩ ចុះថ្ងៃទី ១៦

ខែវិច្ឆិកា ឆ្នាំ ២០០៤

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ១២០ចុះថ្ងៃទី ២៣

ខែ មិថុនា ឆ្នាំ ២០០៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ជាក្រឡាបញ្ជីសវនាការ

**<u>មេធាវី</u>**

លោក [redacted]

សាលក្រមនេះចម្លងត្រូវនឹងច្បាប់ដើម

**ក្រឡាបញ្ជី** [redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២០ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

-ឈ្មោះ **៥ ឥរ** ហៅ **ឥ** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិទួលសង្កែ ឃុំទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃភូមិអូរត្រជាក់ចិត្ត សង្កាត់សំរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ី អូសរទេះ ឪពុកឈ្មោះ **៥ សម** (ស) ម្តាយឈ្មោះ **ស សគង** ( ស ) ប្រពន្ធ កូន គ្មាន ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ ។

**-ជាប់ចោទពីបទ** "បង្ករ<u>បួសដោយចេតនា</u>" ប្រព្រឹត្តនៅភូមិអូរត្រជាក់ចិត្ត សង្កាត់សំរុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ស ឌ** ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់បាដាង មានទីលំនៅ ក្រុម២២ ភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាជនរងគ្រោះ ។

-ឈ្មោះ **ស ណ** ភេទប្រុស អាយុ ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ីអូសរទេះ មានទីលំនៅក្រុម ២២ ភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

CS CamScanner

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៨០ ដសព ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១១០៥ ត.ព.០៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១១៣៧ តព.០៤ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

-កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៦:០០ល្ងាច នៅផ្ទះរបស់ឈ្មោះ ឈ ស ភេទស្រី មានការផឹកស៊ីក្លែមសាច់ឆ្កែក្នុងនោះមានឈ្មោះ ម ជាកូនម្ចាស់ផ្ទះ ឈ្មោះ ស ឆ និងឈ្មោះ ៩ គរ ហៅ គ ។ ក្រោយពីផឹកស៊ីមួយសន្ទុះក៏មានការឈ្លោះគ្នារវាងឈ្មោះ ស ឆ និងឈ្មោះ ៩ គរ ដោយឈ្មោះ ស ឆ ប្រើ ៩ គរ ឱ្យទៅយកកាំបិត ដើម្បីយកមកហាន់សាច់ក្លែមបន្ថែម ប៉ុន្តែ ៩ គរ គេមិនព្រមទៅយកដោយគេនឹកឃើញរឿងអតីតកាលដែលកន្លងមកក្រុមរបស់ ស ឆ បានវាយខ្លួនគេ គួបផ្សំនឹងស្រវឹងស្រាផង ក៏មានគំនិតសងសឹកជាមួយ ស ឆ ក៏ស្ទុះទៅយកកាំបិតលៀមទៅកាប់ ស ឆ ត្រូវចំគុម្ពត្រចៀកខាងស្តាំមួយកាំបិត ឆ្វេងមួយកាំបិត និង ត្រូវដៃមួយកាំបិតទៀត បណ្តាលឱ្យរបួសធ្ងន់ធ្ងររួចក៏យកទៅសំរាកនៅមន្ទីរពេទ្យ ឯជនល្មើសសមត្ថកិច្ចចាប់ខ្លួនបានរហូតដល់សព្វថ្ងៃនៅក្នុងពន្ធនាគារក្រុងព្រះសីហនុ ។

## នាពេលសវនាការ

-ឈ្មោះ ៩ គរ ជាជនជាប់ចោទបានឆ្លើយថា កន្លងមកខ្លួន និង ស ឆ ធ្លាប់មានទំនាស់ពាក្យសំដីជាមួយគ្នាម្តងរួចមកហើយក្នុងពេលរាំលេងក្នុងវត្តវាលមាស ក៏ត្រូវបានក្រុម ស ឆ វាយខ្លួនឡើងហើមមុខ ខ្លួនមិនបានប្តឹងផ្តល់អ្វីនោះទេ ។ ខ្លួនសុំជំរាបទៀតថា កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៤:០០រសៀលខ្លួនអង្គុយផឹកស្រាជាមួយឈ្មោះ ម ឈ្មោះ ខ. ឈ្មោះ ឆ និង ម្នាក់ទៀតមិនស្គាល់ឈ្មោះនាំគ្នាផឹករហូតដល់ម៉ោង ៦ និង ៣០នាទី ឈ្មោះ ខ និង ម្នាក់ទៀតដែលមិនស្គាល់ឈ្មោះគេទៅផ្ទះបាត់ទៅ នៅសល់តែខ្លួន ឈ្មោះ ឆ និង ម ក៏មានការប្រកែកគ្នាពីរឿងឱ្យយកកាំបិតមកហាន់សាច់ក្លែម តែគ្មាននរណាទៅយកទេ ដោយសារចាំគ្នាទៅវិញទៅមក បន្ទាប់មកពិភាក្សាគ្នារឿងអាយុតិច នរណាអាយុតិចជាងគេ គឺទៅយកកាំបិត ខ្លួនក៏ទៅយកកាំបិតផ្គាក់មានដងប្រវែង ៣ តឹក ពេលខ្លួនទៅយកនោះ គឺខ្លួនស្រវឹងយ៉ាងខ្លាំង ពេលមកដល់ខ្លួនក៏កាប់ចំនួន ២ កាំបិតទៅលើឈ្មោះ ស ឆ តែមិនដឹងត្រូវចំកន្លែងណាទេ ពេលនោះដែរឈ្មោះ ម ក៏ចាប់ខ្លួនចងនាំយកឱ្យនគរបាលនៅវាលរេញទាំងយប់ ។ ខ្លួនសុំបញ្ជាក់ថា ការកាប់នេះ គឺខ្លួនកាប់ដោយមិនដឹងខ្លួនទេ ព្រោះខ្លួនស្រវឹងស្រាមិនមានស្មារតីនឹងនំនោះឡើយ ។

-ឈ្មោះ ស ឆ ជាជនរងគ្រោះបានឆ្លើយថា កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៥:០០ល្ងាច ខ្លួនបើកបាំងាងទៅលើផ្លូវដែក ដើម្បីត្រឡប់ពីអូរត្រជាក់ចិត្តទៅវាលរេញវិញ ដើម្បីដឹកអ្នកដំណើរត្រឡប់ទៅផ្ទះរៀង១ខ្លួន ពេលដល់ពពាលខែក៏មានបាំងាងគេមកពីមុខខ្លួន ខ្លួនក៏លើកបាំងាងមកខាងក្រៅផ្លូវរទេះភ្លើងនៅក្បែរផ្ទះគេ ដែលខ្លួនធ្លាប់ស្គាល់ដែរ ពេលនោះម្ចាស់ផ្ទះគេហៅខ្លួនថា គេមកវាលរេញតាមរយៈបាំងាងរបស់ខ្លួនដែរ ពេលនោះខ្លួនក៏ដើរចូលទៅស្រាប់តែកូនម្ចាស់ផ្ទះឈ្មោះ ម ហៅខ្លួនឱ្យចូលហូបស្រាជាមួយគេ ក៏ឃើញឈ្មោះ ៩ គរ នៅទីនោះដែរឈ្មោះ ម ក៏ហុចស្រាមួយកែវមកឱ្យខ្លួន ខ្លួនក៏ផឹកស្រានោះរួចដើរមកបាំងាងវិញកំពុងតែលើកបាំងាងដាក់លើផ្លូវ

CS CamScanner

រទេះភ្លើង ស្រាប់តែឈ្មោះ ៩ តរ ហៅ ត យកកាំបិតមកកាប់ខ្លួនចំគុម្ពត្រចៀកខាងស្តាំមួយកាំបិត ខាងឆ្វេងមួយកាំបិតទៀត ខ្លួនក៏យកដៃរងក៏ត្រូវមួយកាំបិតទៀត ពេលនោះខ្លួនលែងដឹងខ្លួនសន្លប់បាត់ស្មារតីតែម្តង ពេលដឹងខ្លួននៅផ្ទះពេទ្យតែម្តង ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់ និង សំណងថ្លៃព្យាបាលរបួសព្រមទាំងជម្ងឺចិត្តពីខ្លួនទុកឱ្យឪពុកខ្លួនជាអ្នកទាមទារ ។

-ឈ្មោះ អ ណរ ជាដើមបណ្តឹងបានឆ្លើយថា ឈ្មោះ ស ឆ ជាកូនបង្កើតរបស់ខ្លួន ពេលកើតហេតុនោះខ្លួននៅឯចំការចេកឯណោះ នៅពេលព្រឹកប្រហែល ០៦ល្ងាច កូនរបស់ឈ្មោះ ឆ វាប្រាប់ថា អា ឆ ត្រូវគេកាប់ដាច់កហើយត្រូវគេនាំទៅមន្ទីរពេទ្យ ឮដូច្នេះខ្លួនក៏មកវាលរេញក៏ឃើញកូននៅផ្ទះពេទ្យហើយ មិនដឹងខ្លួនទេ គឺវាសន្លប់ ២យប់ ៣ថ្ងៃ ទើបដឹងខ្លួន ។ ខ្លួនដឹងថា ពេទ្យដេរចំនួន ០៣កន្លែង គឺដេរគុម្ពត្រចៀកខាងស្តាំ. គុម្ពត្រចៀកខាងឆ្វេង និងកដៃ ប៉ុន្តែដេរប៉ុន្មានថ្នេរខ្លួនមិនបានដឹងទេ ។ ចំពោះបញ្ហានេះខ្លួនក្នុងនាមជាអាណាព្យាបាល ខ្លួនទាមទារថ្លៃថ្នាំព្យាបាលរបួសចំនួន ២.០០០.០០០៛ ( ពីរលានរៀល ) ។

-ឈ្មោះ ឈ ស ជាសាក្សីបានឆ្លើយថា នៅថ្ងៃកើតហេតុនេះខ្លួនដឹងថា ឈ្មោះ ឆ. ឈ្មោះ ៩ តរ ឈ្មោះ ម និង ឈ្មោះ ខ និង ឈ្មោះ ឃ នាំផឹកស្រាក្លែមសាច់ឆ្អែ ផឹកបានមួយសន្ទុះគេចេញទៅអស់នៅសល់ ឆ និង ៩ តរ តែពីរនាក់ប៉ុណ្ណោះ ខ្លួនក៏ទៅងូតទឹក ពេលត្រឡប់មកវិញ កំពុងតែសិតសក់ ស្រាប់តែឮភ្ញូស១ ខ្លួនក៏ក្រឡេកទៅឃើញឈ្មោះ ៩ តរ កាប់ទៅលើឈ្មោះ ឆ ចំនួន ២ កាំបិត ខ្លួនឃើញដូច្នេះ ខ្លួនស្ទុះរត់ទៅបុកចំក្បាលពោះឈ្មោះ តរ ហៅ ត នេះ ឈ្មោះ ត ក៏ខ្ទាតទៅក្បែរជញ្ជាំង ស្រាប់តែពេលនោះឈ្មោះ ៩ តរ បានទាញកាំបិតបំរុងកាប់ខ្លួនទៀត ក៏ប្តីខ្លួនចាប់កដៃកាន់កាំបិតជាប់ ហើយកូនរបស់ខ្លួនឈ្មោះ ម ក៏មកអោប ត ពីក្រោយជាប់ទៀត ក៏យកខ្សែមកចង ត ហើយយកម៉ូតូដឹក ឌ មកដឹក ត ទៅនគរបាលខណ្ឌព្រៃនប់ និង នាំជនរងគ្រោះមកផ្ទះពេទ្យតែម្តង ឯរឿងរ៉ាវអ្វីទៀតខ្លួនមិនបានដឹងឡើយ ។

-ឈ្មោះ យ សឆរ ជាសាក្សីបានឆ្លើយថា នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៧ និង ៣០នាទីយប់ មានជនរងគ្រោះឈ្មោះ ស ឆ បានចូលផ្ទះខ្លួន ដោយមានរបួស គឺអញ្ចឹងកខាងស្តាំប្រវែង ៨ សម ជម្រៅ ១ សម នៅលើកញ្ចឹងកខាងឆ្វេងប្រវែង ៧សម ជម្រៅ ១សម របួសចង្កូលដៃខាងឆ្វេងប្រវែង ១.៥សម ជម្រៅ ១សម របួសមេដៃឆ្វេងប្រវែង ១សម ជម្រៅ ០.៥សម ។ កញ្ចឹងកខាងស្តាំ និង ខាងឆ្វេងក្នុងមួយកន្លែង គឺដេរ ០៨ ថ្នេរ ជនរងគ្រោះសំរាក ៣ ថ្ងៃ ឬ ៤ ថ្ងៃ ក៏ចេញពីផ្ទះខ្លួនទៅ ។ ឯរឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនដឹងឡើយ ។

-ឈ្មោះ ខ សផ ជាសាក្សីបានឆ្លើយថា នៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ៨ ជាងយប់ ឈ្មោះ ៩ ម បាននាំឈ្មោះ ៩ តរ ហៅ ត មកដល់កន្លែងសមត្ថកិច្ចនគរបាលខ័ណ្ឌព្រៃនប់តែម្តង ហើយក៏ប្រគល់ជនល្មើសឱ្យសមត្ថកិច្ច ក៏គាត់ត្រឡប់ទៅមូលដ្ឋានវិញទៅ ខ្លួនក៏ឃាត់ខ្លួនជនល្មើស និងធ្វើកំណត់ហេតុកសាងសំណុំរឿងបញ្ជូនជនល្មើសមកស្នងការនគរបាលក្រុងព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធីតទៅទៀត ។

-បានឃើញលិខិតវេជ្ជបញ្ជារបស់គ្រូពេទ្យព្យាបាលជម្ងឺ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤ បានបញ្ជាក់ថា ឈ្មោះ ស ឆ ភេទប្រុស អាយុ ២១ ឆ្នាំ បានចូលពិនិត្យរបួសនៅថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៤ វេលាម៉ោង ១៩ និង ៣០នាទី ដែលមានស្លាកស្នាមដូចខាងក្រោមនេះ :

-របួសកញ្ចឹងកខាងស្តាំប្រវែង ៨ សម ជម្រៅ ១ សម

-របួសកញ្ចឹងកខាងឆ្វេងប្រវែង ៧ សម ជម្រៅ ១ សម

-របួសចង្កូលដៃខាងឆ្វេងប្រវែង ១.៥ សម ជម្រៅ ០.៥ សម

-របួសមេដៃខាងឆ្វេងប្រវែង ១ សម ជម្រៅ ០.៥ សម

CamScanner

-បានឃើញកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ ដែលបានទទួលកាំបិតល្មៀមដងឈើចំនួន ០១ ដើម ពីសមត្ថកិច្ចនគរបាលក្រុងព្រះសីហនុ ។

-តំណាងអយ្យការបានធ្វើការសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ៩ គះ ហៅ គ ពីបទបង្ករបួសដោយចេតនា ហើយការប្រព្រឹត្តរបស់ជនល្មើស គឺធ្វើឡើងដោយមានអាវុធ របួសក៏មានលក្ខណៈធ្ងន់ធ្ងរដែរ ហេតុនេះសុំឱ្យចៅក្រមវិនិច្ឆ័យទៅតាមច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងមាត្រា ៤១ ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនបានប្រព្រឹត្តទៅលើជនរងគ្រោះនោះ គឺគាត់ស្ថិតនៅក្នុងលក្ខណៈស្រវឹងស្រាធ្វើឱ្យអារម្មណ៍ ឬ ស្មារតីរបស់គាត់មិននឹងនំ ការប្រព្រឹត្តរបស់គាត់គ្មានការទទួលខុសត្រូវ និង មិនដឹងខ្លួនឡើយ ហេតុនេះសុំឱ្យចៅក្រមជំនុំជំរះមេត្តាជួយអនុគ្រោះដល់កូនក្តីខ្លួនផង ។

-ជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ថា ពេលខ្លួនកាប់ទៅលើជនរងគ្រោះ គឺខ្លួនមិនដឹងខ្លួនឡើយ ព្រោះថ្ងៃកើតហេតុនោះ គឺបានផឹកស្រា ហើយស្រវឹងយ៉ាងខ្លាំង ធ្វើឱ្យខ្លួនមិនមានស្មារតីរឹងប៉ឹង ហើយខ្លួនគ្មានចេតនាក្នុងការកាប់ជនរងគ្រោះឱ្យរបួសយ៉ាងដូច្នេះដែរ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

**តុលាការក្រុងព្រះសីហនុ**

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

-តាមការអះអាងរបស់ ស ឆ ជាជនរងគ្រោះ បានឆ្លើយបញ្ជាក់ថា ឈ្មោះ ៩ គះ ហៅ គ បានយកកាំបិតល្មៀមកាប់ខ្លួនជាច្រើនកាំបិតបណ្តាលឱ្យខ្លួនមានរបួសនៅគុម្ពត្រចៀកទាំងសងខាង និង ដៃ ព្រមទាំងដេរអស់ជាច្រើនថ្នេរដែរ ។

-តាមការឆ្លើយបញ្ជាក់របស់ជនជាប់ចោទថា ពេលកើតហេតុ គឺខ្លួនស្រវឹងស្រាយ៉ាងខ្លាំង ការកាប់នេះក៏កាប់ដោយមិនដឹងខ្លួនដែរ គឺគ្មានចេតនាទៅលើឈ្មោះ ស ឆ នោះឡើយ ក៏ប៉ុន្តែឈ្មោះនេះបានបញ្ជាក់ទៀតថា កន្លងមកខ្លួនពេ និង ស ឆ ធ្លាប់មានទំនាស់គ្នាម្តងរួចមកហើយ នៅក្នុងវត្តវាលមាស និង តាមចម្លើយសាក្សីនៅពេលកើតហេតុគេឃើញច្បាស់ថា ឈ្មោះ ស ឆ និង ៩ គះ មានទំនាស់ពាក្យសំដីគ្នាម្តងទៀត ដែលជាហេតុធ្វើឱ្យឈ្មោះ ៩ គះ មានកំហឹង កាលពីលើកមុនផង និង លើកនេះទៀត ទ្រាំមិនបានក៏កាប់ទៅលើឈ្មោះ ស ឆ នេះទៅ ។

-ការកាប់នេះមិនមែនលើកហេតុផលស្រវឹងស្រានោះឡើយ គឺឈ្មោះនេះមានចេតនាតែម្តង កាំបិត គឺជាអាវុធដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិត តែដោយសារឈ្មោះ ស ឆ គេចចុះគេចឡើង បណ្តាលឱ្យត្រូវគុម្ពត្រចៀកទាំងសងខាងយ៉ាងដូច្នេះ និង ត្រូវកដៃក៏ដោយសារយកដៃរបស់គាត់រងដែរ ។

CamScanner

-តាមចម្លើយសាក្សីនៅជុំវិញកើតហេតុបានបញ្ជាក់ថា ឈ្មោះ ៩ គះ ពិតជាបានកាន់កាំបិតល្មៀមកាប់ទៅលើឈ្មោះ ស ឆ នៅកន្លែងកើតហេតុក្នុងពេលទាស់ពាក្យសំដីគ្នាមែន ចម្លើយនេះមានមូលដ្ឋានគ្រប់គ្រាន់គួរឱ្យតុលាការជឿបាន ។

-កាំបិត គឺជាអាវុធដ៏មុតស្រួច ក្នុងច្បាប់ក៏បានចែងថា បើការវាយតប់នោះធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ គឺរិតទោសត្រូវទ្វេមួយជាពីរ ។

-លិខិតបញ្ជាក់របស់វេជ្ជបញ្ជារគ្រូពេទ្យព្យាបាលជម្ងឺបានបញ្ជាក់ពីមុខរបួសលើឈ្មោះ ស ឆ មានទំហំប្រវែង និង ជម្រៅ នៅលើកញ្ចឹងកក្បែរគុម្ពត្រចៀកខាងឆ្វេង ខាងស្តាំ និង ដៃ មានមូលដ្ឋានគ្រប់គ្រាន់គួរឱ្យតុលាការយកជាការបាន ។

-បណ្តឹងទាមទារសំណង និង ថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តមានលក្ខណៈសមស្របតាមច្បាប់ គប្បីតុលាការពិនិត្យ និង ពិចារណាដល់បញ្ហានេះ ។

-ចម្លើយសាក្សីមានមូលដ្ឋានគ្រប់គ្រាន់អាចឱ្យតុលាការយកជាការបាន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ៩ គះ ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់សំរ៉ុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២00៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

## ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ

## សំរេច

១-ឈ្មោះ ៩ គះ ហៅ គ ភេទប្រុស អាយុ ២៦ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ 0២ ឆ្នាំ (ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២00៤ ។

ពីបទ : **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅភូមិអូរត្រជាក់ចិត្ត សង្កាត់សំរ៉ុង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២00៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ ៩ គះ ហៅ គ សងសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២.000. 000៛00 (ពីរលានរៀល) ទៅជនរងគ្រោះឈ្មោះ ស ឆ ដែលមានឈ្មោះ អ ឈា ជាដើមបណ្តឹង ចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-វត្ថុតាង : កាំបិតល្មៀមដងឈើ ចំនួន 0១ ដើម ត្រូវរឹបអូសបំផ្លាញចោល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងមេធាវី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]